**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សាធម្មនុញ្ញ**

**សំណុំរឿង**
លេខ : ០៨៧/០១០ /២០០៤
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤
**សេចក្តីសម្រេច**
លេខ : ០៦៤/០០៦/២០០៤ កបធ.ច
ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

# ក្រុមប្រឹក្សាធម្មនុញ្ញ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ ១៩៩៣
-បានឃើញព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញ
-បានឃើញលិខិតលេខ ២៥៥ រស ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ របស់សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី ដែលស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ

**ក្រោយពីបានស្តាប់របាយការណ៍របស់សមាជិករាយការណ៍**
**ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ**

- យល់ឃើញថា សម្តេច **ហេង សំរិន** ប្រធានរដ្ឋសភាស្តីទី បានផ្ញើលិខិតលេខ ២៥៥ រស ចុះថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ មកឯកឧត្តមប្រធានក្រុមប្រឹក្សាធម្មនុញ្ញ ស្នើសុំឱ្យក្រុមប្រឹក្សាធម្មនុញ្ញពិនិត្យធម្មនុញ្ញភាពនៃច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ហើយដែលអគ្គលេខាធិការដ្ឋានក្រុមប្រឹក្សា-ធម្មនុញ្ញបានទទួលនៅថ្ងៃខែឆ្នាំដដែល វេលាម៉ោង ១១:១៥ ព្រឹក ។ ដូច្នេះក្រុមប្រឹក្សាធម្មនុញ្ញអាចទទួលយកសំណើនេះមកពិនិត្យបាន ដោយស្របតាមមាត្រា ១៣៦ ថ្មី មាត្រា ១៤០ ថ្មី នៃរដ្ឋធម្មនុញ្ញ និង មាត្រា ១៥ មាត្រា ១៦ នៃច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សាធម្មនុញ្ញដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៤៩៨/០៦ ចុះថ្ងៃទី ០៨ ខែ មេសា ឆ្នាំ ១៩៩៨ ។
- យល់ឃើញថា ច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ត្រូវបានតាក់តែងឡើងក្រោយពីព្រះមហាក្សត្រទ្រង់បានផ្ញើព្រះរាជសាររបស់ព្រះអង្គ ចុះថ្ងៃទី ០៦ ខែ តុលា ឆ្នាំ ២០០៤ ផ្ញើថ្វាយប្រគេន ព្រះសង្ឃ និង ជូនជនរួមជាតិដើម្បីសុំចូលនិវត្តន៍ ហើយបើតាមខ្លឹមសារនៃព្រះរាជសារនេះ និងព្រះរាជសារបន្តបន្ទាប់ ការចូលនិវត្តន៍ គឺការដាក់រាជសម្បត្តិ ។ ព្រះរាជសាររបស់ព្រះករុណាជាអម្ចាស់ជីវិតតម្កល់លើត្បូងមានអានុភាពខ្ពស់បំផុត ។

- យល់ឃើញថា ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនេះ មាន ៥ ជំពូក ចែកចេញជា ១៨ មាត្រា ។

**១-ជំពូកទី ១**

ជំពូកនេះ មាន ២ មាត្រា ហើយចែងអំពីបទបញ្ញត្តិទូទៅ ពាក់ព័ន្ធនឹងគោលដៅនៃច្បាប់ និង សមត្ថកិច្ចរបស់ក្រុមប្រឹក្សារាជសម្បត្តិ ដែលជាអ្នកជ្រើសតាំងព្រះមហាក្សត្រថ្មី ។ ត្រង់នេះ គឺស្របនឹងមាត្រា ១០ នៃរដ្ឋធម្ម-នុញ្ញ វាក្យខ័ណ្ឌ ទី ១ ដែលចែងថា " *របបរាជានិយមកម្ពុជា ជារបបជ្រើសតាំង* " ហើយនិងមាត្រា ១៣ ថ្មី នៃរដ្ឋធម្មនុញ្ញ វាក្យខ័ណ្ឌ ទី ៣ ដែលចែងថា " *ការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិនឹងមានកំណត់ក្នុងច្បាប់មួយ* " ។ ជំពូកទី ១ ទាំងមូលស្របនឹងរដ្ឋធម្មនុញ្ញ ។

**២-ជំពូកទី ២**

ជំពូកនេះ មាន ៥ មាត្រា ពាក់ព័ន្ធនឹងការរៀបចំ និង សមាសភាពនៃក្រុមប្រឹក្សារាជសម្បត្តិ ហើយបញ្ជាក់អំពីតួនាទី និង ភារកិច្ចរបស់ប្រធាន អនុប្រធាន និង រដ្ឋមន្ត្រីក្រសួងព្រះបរមរាជវាំង ដែលត្រូវរក្សាកំណត់ហេតុ និងឯកសារទាំងអស់របស់ក្រុមប្រឹក្សារាជសម្បត្តិ មិនឱ្យខូចខាតបានឡើយ ។ ក្រុមប្រឹក្សារាជសម្បត្តិមានប្រធានព្រឹទ្ធសភាជាប្រធាន និង អនុប្រធាន ២ រូប គឺ ប្រធានរដ្ឋសភាជាអនុប្រធានទី ១ និង នាយករដ្ឋមន្ត្រី ជាអនុប្រធានទី ២ ។ ក្រៅពីនេះ មានសមាជិក ៦ រូបទៀត ដូចមានចែងក្នុងមាត្រា ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ។ ដូច្នេះ ជំពូកទី ២ ទាំងមូលស្របនឹងមាត្រា ១៣ ថ្មីនៃរដ្ឋធម្មនុញ្ញ ។

**៣-ជំពូកទី ៣**

ក្នុងជំពូក នេះមាន ៨ មាត្រា ពាក់ព័ន្ធនឹងការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដូចជារបៀបធ្វើការប្រជុំ កូរ៉ុម ការសម្ងាត់នៃការពិភាក្សា ការអនុម័ត ការបោះឆ្នោតសម្ងាត់ ការជ្រើសរើសជាព្រះមហាក្សត្រ ក្នុងចំណោមសមាជិកនៃព្រះរាជវង្សានុវង្ស ដូចមានចែងក្នុងមាត្រា ១៤ នៃរដ្ឋធម្មនុញ្ញ ការធ្វើសច្ចាប្រណិធាន ការផ្សព្វផ្សាយសេចក្តីសម្រេចស្តីពីការជ្រើសរើសព្រះមហាក្សត្រថ្មី និង ការធ្វើព្រះរាជពិធីអភិសេកជាដើម ។ ដោយឡែកមាត្រា ១០ ដោយសារការសុំចូលនិវត្តន៍ គឺជាការដាក់រាជសម្បត្តិ ដូចបានបញ្ជាក់ក្នុងការយល់ឃើញខាងលើ ដូច្នេះជំពូកទី ៣ ស្របនឹងរដ្ឋធម្មនុញ្ញ ។

**៤-ជំពូកទី ៤ និង ទី ៥**

ជំពូកទាំងពីរនេះពុំមានបទបញ្ញត្តិណាផ្ទុយនឹងរដ្ឋធម្មនុញ្ញឡើយ ។

## សម្រេច

**មាត្រា ១.-** ច្បាប់ស្តីពីការរៀបចំ និង ការប្រព្រឹត្តទៅនៃក្រុមប្រឹក្សារាជសម្បត្តិ ដែលមាន ៥ ជំពូក និង ១៨ មាត្រា ត្រូវបានប្រកាសថា ស្របនឹងរដ្ឋធម្មនុញ្ញ ។

**មាត្រា ២.-** សេចក្តីសម្រេចនេះ ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤ នាសម័យប្រជុំពេញអង្គនៃក្រុមប្រឹក្សាធម្មនុញ្ញ និង ជាសេចក្តីសម្រេចស្ថាពរ បិទផ្លូវតវ៉ា ហើយមានអានុភាពអនុវត្តទៅលើអំណាចទាំងអស់ ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ និង ត្រូវចុះផ្សាយក្នុងរាជកិច្ច ។

រាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ តុលា ឆ្នាំ ២០០៤

**ជ.ក្រុមប្រឹក្សាធម្មនុញ្ញ**

**ប្រធាន**

**ប៊ិន ឈិន**